**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងទេសចរណ៍**

**លេខ** ១៤៧ / បក

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៧

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ០៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងទេសចរណ៍

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

[illegible] ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: + ៨៥៥ ២៣ ៨៨៤ ៩៧២ ទូរសារ: + ៨៥៥ ២៣ ៨៨៤ ៩៧៤ E-mail: admin@mot.gov.kh Website: www.tourismcambodia.org

**ប្រការ ២.-**

ប្រកាសនេះមានគោលដៅដូចខាងក្រោម៖

- ធានាប្រសិទ្ធភាពការងារ និងការទទួលខុសត្រូវរបស់នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍នៃក្រសួងទេសចរណ៍
- បង្កើត និងបង្កើនយន្តការលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលក្នុងវិស័យទេសចរណ៍ ពិសេសជម្រុញការអភិវឌ្ឍជំនាញវិជ្ជាជីវៈទេសចរណ៍ឱ្យស្របតាមកម្រិតជាតិ និងអន្តរជាតិ អាស៊ាន តំបន់ និងពិភពលោក ឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍
- ធានានូវការគ្រប់គ្រងវិស័យទេសចរណ៍ដោយឈរលើគោលការណ៍និរន្តរភាព និងការទទួលខុសត្រូវ។

## **ជំពូកទី ២**
## **តួនាទី និងភារកិច្ច**

**ប្រការ ៣.-**

**នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍** ចំណុះអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ និងជាសេនាធិការឲ្យក្រសួងទេសចរណ៍ ទទួលបន្ទុកការងារបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។

**នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍** មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងបដិសណ្ឋារកិច្ច
- ត្រួតពិនិត្យលើរាល់សាលាជាតិបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលគ្រប់គ្រងដោយរដ្ឋ
- រៀបចំបង្កើត និងធ្វើបច្ចុប្បន្នកម្មបទដ្ឋានគតិយុត្ត ស្តង់ដារអប្បបរមា កម្មវិធីសិក្សា ស្តង់ដាសមត្ថភាពជំនាញវិជ្ជាជីវៈ និងការអនុវត្តនានាដើម្បីត្រួតពិនិត្យ តាមដាន កែលម្អ និងរក្សាគុណភាពអប់រំបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យទេសចរណ៍ឲ្យស្របតាមកម្រិតជាតិ និងអន្តរជាតិ អាស៊ាន តំបន់ និងពិភពលោក និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការគ្រប់គ្រង ត្រួតពិនិត្យ ទទួលស្គាល់រាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍គ្រប់គ្រងដោយឯកជន និងអង្គការមិនមែនរដ្ឋាភិបាលលើកម្មវិធីសិក្សា ស្របតាមកម្មវិធីសិក្សាជាតិ អាស៊ាន និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយក្រសួង ស្ថាប័ន ផ្នែកពាក់ព័ន្ធ ដើម្បីបញ្ចូលកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍នៅតាមគ្រឹះស្ថានអប់រំនានា
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួង ស្ថាប័ន ផ្នែកពាក់ព័ន្ធក្នុងការគ្រប់គ្រង និងត្រួតពិនិត្យកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍
- សហការជាមួយនាយកដ្ឋានធនធានមនុស្ស នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន និងភាគីពាក់ព័ន្ធ រៀបចំផែនការយុទ្ធសាស្ត្រ និងស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីធ្វើការបណ្តុះបណ្តាលមន្ត្រីរាជការនៅទីស្តីការក្រសួង និងមន្ទីរទេសចរណ៍រាជធានី ខេត្ត
- ជាលេខាធិការដ្ឋានឱ្យគណៈកម្មាធិការជាតិអ្នកជំនាញទេសចរណ៍
- សហការអនុវត្តវិធានការ និងរៀបចំកម្មវិធីបណ្តុះបណ្តាលនានាសំដៅលើកកម្ពស់ និងធានាគុណភាពធនធានមនុស្សក្នុងវិស័យទេសចរណ៍
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់អគ្គនាយកគ្រប់គ្រងឧស្សាហកម្មទេសចរណ៍។

នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដឹកនាំដោយប្រធាន **មួយ (០១) រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ

**ប្រការ ៤.-**

នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ មានការិយាល័យចំណុះចំនួន **០៧(ប្រាំពីរ)** ដូចខាងក្រោម៖

១-ការិយាល័យសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

២-ការិយាល័យវាយតម្លៃ និងទទួលស្គាល់អ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន

៣-ការិយាល័យគុណភាព និងស្តង់ដា

៤-ការិយាល័យជម្រុញការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន

៥-ការិយាល័យបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍

៦-ការិយាល័យបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍

៧-ការិយាល័យចុះបញ្ជី និងទីផ្សារការងារជំនាញវិជ្ជាជីវៈទេសចរណ៍។

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធាន **មួយ(០១)រូប** និងអនុប្រធានមួយចំនួនតាមការចាំបាច់អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខរបស់នាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី ៤
## តួនាទី និងភារកិច្ចរបស់ការិយាល័យ

**ប្រការ ៥.-**

ការិយាល័យនីមួយៗ មានតួនាទី និងភារកិច្ចដូចតទៅ៖

**១-ការិយាល័យសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍** មានតួនាទី និងភារកិច្ច៖

- ត្រួតពិនិត្យលើរាល់សាលាជាតិបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដែលគ្រប់គ្រងដោយរដ្ឋ
- រៀបចំឱ្យមានការលើកទឹកចិត្ត និងផ្តល់រង្វាន់ជូនសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍គំរូ
- គ្រប់គ្រង និងអភិវឌ្ឍបណ្ណាល័យក្រសួងទេសចរណ៍ ដោយស្វែងរកប្រភពផ្គត់ផ្គង់សៀវភៅផ្សេងៗ
- សហការគ្រប់គ្រងត្រួតពិនិត្យ ទទួលស្គាល់រាល់សាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍គ្រប់គ្រងដោយឯកជន និងអង្គការមិនមែនរដ្ឋាភិបាលលើសាស្ត្រាចារ្យ គ្រូបង្គោល និងគ្រូឧទ្ទេសជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច និងកម្មវិធីសិក្សា ស្របតាមកម្មវិធីសិក្សាជាតិ អាស៊ាន និងលក្ខខណ្ឌអនុវត្តដ៏ប្រសើរនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- សហការជាមួយក្រសួង ស្ថាប័ន ផ្នែកពាក់ព័ន្ធដើម្បីបញ្ចូលកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍នៅតាមគ្រឹះស្ថានអប់រំនានា
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងស្ថាប័នផ្នែកពាក់ព័ន្ធក្នុងការគ្រប់គ្រង និងត្រួតពិនិត្យកម្មវិធីសិក្សាជំនាញវិជ្ជាជីវៈទេសចរណ៍ សាស្ត្រាចារ្យគ្រូបង្គោល និងគ្រូឧទ្ទេសជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច
- សហការជាមួយដៃគូអភិវឌ្ឍន៍ជម្រុញការសាងសង់គ្រឹះស្ថានសិក្សាទេសចរណ៍ និងបដិសណ្ឋារកិច្ច និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងសម្បទានទ្រទ្រង់ដល់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍។

**២-ការិយាល័យវាយតម្លៃ និងទទួលស្គាល់អ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន** មានតួនាទី និងភារកិច្ចៈ

- រៀបចំ និងធ្វើបច្ចុប្បន្នកម្មយន្តការវាយតម្លៃទទួលស្គាល់គុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន
- រៀបចំយន្តការវាយតម្លៃ និងទទួលស្គាល់មជ្ឈមណ្ឌលវាយតម្លៃ (Assessment Centers) និងមជ្ឈមណ្ឌលគំរូ (Center of Excellence) ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន
- សិក្សា និងរៀបចំផែនការវាយតម្លៃអ្នកជំនាញទេសចរណ៍ រួមទាំងការវាយតម្លៃការសិក្សាពីមុន (Recognition of Prior Learning)
- រៀបចំ និងធ្វើបច្ចុប្បន្នកម្មយន្តការ និងឧបករណ៍វាយតម្លៃអ្នកជំនាញទេសចរណ៍តាមកម្រិតគុណវុឌ្ឍិអាស៊ាន និងសមត្ថភាពនីមួយៗ
- វាយតម្លៃគុណវុឌ្ឍិ និងសមត្ថភាពអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន
- រៀបចំឯកសារស្នើចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន ទៅលេខាធិការដ្ឋានតំបន់ទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន
- វាយតម្លៃ ទទួលស្គាល់ និងធ្វើបច្ចុប្បន្នកម្មគុណវុឌ្ឍិ និងសមត្ថភាពអ្នកវាយតម្លៃចល័ត និងអ្នកវាយតម្លៃបង្គោលជាតិ និងអាស៊ាន
- ផ្សព្វផ្សាយស្តង់ដា និងយន្តការនានាទ្រទ្រង់ការវាយតម្លៃ និងទទួលស្គាល់អ្នកជំនាញទេសចរណ៍អាស៊ាន
- អនុវត្តសកម្មភាពការងារផ្សេងៗទៀត ស្របតាមផែនការសកម្មភាពអាស៊ាន (ASEAN MRA-TP Work Plan)
- សហការជាមួយគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដើម្បីទទួលស្គាល់កម្រិតគុណវុឌ្ឍិដែលបានវាយតម្លៃ
- សហការជាមួយលេខាធិការដ្ឋានតំបន់ទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ានដើម្បីពង្រឹងសមត្ថភាពអ្នកវាយតម្លៃបង្គោលជាតិ និងអាស៊ាន
- សហការជាមួយភាគីឯកជន អង្គការជាតិ អន្តរជាតិ និងដៃគូរអភិវឌ្ឍន៍ ដើម្បីជម្រុញការវាយតម្លៃអ្នកជំនាញទេសចរណ៍អាស៊ាន ស្របតាមយន្តការនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន។

**៣-ការិយាល័យគុណភាព និងស្តង់ដា** មានតួនាទី និងភារកិច្ចៈ

- ធ្វើបច្ចុប្បន្នកម្មស្តង់ដាសមត្ថភាព កម្មវិធីបណ្តុះបណ្តាល និងឧបករណ៍បណ្តុះបណ្តាលរបស់ជំនាញទេសចរណ៍អាស៊ាន ស្របតាមស្មារតីនៃកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន
- អភិវឌ្ឍស្តង់ដាសមត្ថភាព កម្មវិធីបណ្តុះបណ្តាល និងឧបករណ៍បណ្តុះបណ្តាលជំនាញទេសចរណ៍អាស៊ានថ្មីៗ
- តាមដាន និងវាយតម្លៃគុណភាពការងារតាមជំនាញនីមួយៗ របស់អ្នកជំនាញទេសចរណ៍អាស៊ាន
- អភិវឌ្ឍ និងធ្វើបច្ចុប្បន្នកម្មកញ្ចប់គុណវុឌ្ឍិជាតិ និងអាស៊ាន ដើម្បីទ្រទ្រង់ការបណ្តុះបណ្តាល និងវាយតម្លៃអ្នកជំនាញទេសចរណ៍អាស៊ាន
- រៀបចំយន្តការជម្រុញការបណ្តុះបណ្តាលខាងក្នុង (In-House Training) តាមស្តង់ដាអាស៊ាន
- រៀបចំយន្តការជម្រុញការហ្វឹកហាត់សមត្ថភាពអ្នកជំនាញទេសចរណ៍អាស៊ាន (Apprenticeship Programme)
- រៀបចំយន្តការកំណត់កាតព្វកិច្ចបណ្តុះបណ្តាល (Training Obligation)
- រៀបចំយន្តការធានាគុណភាពបណ្តុះបណ្តាលស្តង់ដាអាស៊ាន

- ចេញវិញ្ញាបនបត្រ សញ្ញាបត្រ ដល់សិស្សានុសិស្សក្រោយបញ្ចប់ការបណ្ដុះបណ្ដាល និងវាយតម្លៃស្របតាមស្តង់ដាអាស៊ាន
- ចេញវិញ្ញាបនបត្របញ្ជាក់គុណភាពបណ្ដុះបណ្ដាលជំនាញទេសចរណ៍អាស៊ាន
- អនុវត្តយន្តការគ្រប់គ្រង និងបណ្ដុះបណ្ដាលគ្រូបង្គោលជាតិ និងអាស៊ាន
- រៀបចំ និងកត់ត្រាគុណវុឌ្ឍិអ្នកជំនាញទេសចរណ៍ ក្នុងសៀវភៅអ្នកជំនាញទេសចរណ៍ (Tourism Skill Passports)
- អភិវឌ្ឍកម្មវិធីសិក្សាតាមប្រព័ន្ធអនឡាញ (E-Learning Programme)
- ផ្សព្វផ្សាយយន្តការនានាទ្រទ្រង់ការអនុវត្តគុណភាព និងស្តង់ដាសមត្ថភាពអ្នកជំនាញទេសចរណ៍អាស៊ាន
- អនុវត្តសកម្មភាពការងារផ្សេងៗទៀតស្របតាមផែនការសកម្មភាពអាស៊ាន(ASEAN MRA-TP Work Plan)
- សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីតម្រង់ទិសការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន តាមវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស និងគ្រឹះស្ថានអប់រំ និងបណ្ដុះបណ្ដាលផ្សេងៗទៀត
- សហការជាមួយគណៈកម្មាធិការជាតិបណ្ដុះបណ្ដាលដើម្បីទទួលស្គាល់កម្រិតគុណវុឌ្ឍិដែលបានវាយតម្លៃ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ភាគីឯកជន អង្គការជាតិ អន្តរជាតិ ដៃគូរអភិវឌ្ឍន៍ និងលេខាធិការដ្ឋានតំបន់ទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ានដើម្បីអភិវឌ្ឍស្តង់ដាសមត្ថភាពកម្មវិធីបណ្ដុះបណ្ដាលនិងឧបករណ៍បណ្ដុះបណ្ដាលជំនាញទេសចរណ៍ស្របតាមស្តង់ដាជាតិ អាស៊ាន តំបន់ និងអន្តរជាតិ។

**៤-ការិយាល័យជម្រុញការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមក នៃអ្នកជំនាញទេសចរណ៍អាស៊ាន** មានតួនាទី និងភារកិច្ចៈ

- ពង្រឹងការបញ្ជ្រាបការយល់ដឹង និងពង្រឹងសមត្ថភាពលើការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន
- ជម្រុញការផ្លាស់ប្តូរព័ត៌មាន និងការទំនាក់ទំនងជាមួយលេខាធិការដ្ឋានតំបន់ទទួលបន្ទុកការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន
- រៀបចំរបាយការណ៍ និងចូលរួមកិច្ចប្រជុំក្រុមការងារ ឬគណៈកម្មការទទួលបន្ទុកជំនាញអាស៊ាន
- រៀបចំអនុស្សរណៈយោគយល់គ្នាលើកិច្ចសហប្រតិបត្តិការពាក់ព័ន្ធនឹងការអភិវឌ្ឍសមត្ថភាព និងបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈទេសចរណ៍អាស៊ាន
- រៀបចំផែនការអភិវឌ្ឍជំនាញវិជ្ជាជីវៈទេសចរណ៍ស្របតាមនិន្នាការអាស៊ាន
- រៀបចំគោលការណ៍ណែនាំ និងឯកសារគាំទ្រការប្រកួតជំនាញទេសចរណ៍អាស៊ាន
- បង្កើត រចនា អភិវឌ្ឍ និងធ្វើបច្ចុប្បន្នភាពលើគេហទំព័រ **គ.ជ.អ.ទ.**
- សម្របសម្រួលផ្លាស់ប្តូរព័ត៌មានតាមគ្រប់មធ្យោបាយ លើកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន
- សម្របសម្រួលការចុះឈ្មោះអ្នកជំនាញទេសចរណ៍ទៅក្នុងប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន
- តាមដាន និងត្រួតពិនិត្យទិន្នន័យអ្នកជំនាញទេសចរណ៍អាស៊ាន ដើម្បីគ្រប់គ្រងការបម្លាស់ទី
- កត់ត្រាគុណវុឌ្ឍិគ្រូឧទ្ទេស គ្រូចល័ត គ្រូបង្គោល អ្នកវាយតម្លៃចល័ត និងអ្នកវាយតម្លៃបង្គោលក្នុងប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន (ATPRS)

- រៀបចំ និងកត់ត្រាសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ក្នុងប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន (ATPRS)
- រៀបចំគោលការណ៍ណែនាំ និងឯកសារគាំទ្រការប្រកួតជំនាញទេសចរណ៍អាស៊ាន
- អភិវឌ្ឍឧបករណ៍ជំនួយការបណ្តុះបណ្តាលរួមមាន វីដេអូឃ្លីប និងឯកសារបណ្តុះបណ្តាលផ្សេងៗ និងដាក់បញ្ចូលក្នុងគេហទំព័រ គ.ជ.អ.ទ
- ផ្សព្វផ្សាយយន្តការនានាទ្រទ្រង់ការចុះបញ្ជីអ្នកជំនាញទេសចរណ៍អាស៊ាន
- អនុវត្តសកម្មភាពការងារផ្សេងៗទៀត ស្របតាមផែនការសកម្មភាពអាស៊ាន (ASEAN MRA-TP Work Plan)
- សហការជាមួយលេខាធិការដ្ឋានតំបន់ទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀង MRA ដើម្បីគ្រប់គ្រងទិន្នន័យអ្នកជំនាញទេសចរណ៍អាស៊ាន
- សហការជាមួយលេខាធិការដ្ឋានតំបន់ទទួលបន្ទុកអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន ដើម្បីតាមដាន និងជម្រុញការអនុវត្តកិច្ចព្រមព្រៀងទទួលស្គាល់គ្នាទៅវិញទៅមកនៃអ្នកជំនាញទេសចរណ៍អាស៊ាន។

**៥-ការិយាល័យបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំផែនការយុទ្ធសាស្ត្របណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ និងបដិសណ្ឋារកិច្ច
- រៀបចំបើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍លើគ្រប់ជំនាញ គ្រប់ទម្រង់ និងគ្រប់កម្រិត
- ចេញវិញ្ញាបនបត្របណ្តុះបណ្តាលដល់អ្នកជំនាញទេសចរណ៍លើគ្រប់ជំនាញ និងគ្រប់កម្រិត
- រៀបចំបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល
- បង្កើតក្រុមគ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោលចល័ត
- រៀបចំឱ្យមានការលើកទឹកចិត្ត និងផ្តល់រង្វាន់ជូនគ្រូឧទ្ទេស គ្រូបង្គោល និងអ្នកវាយតម្លៃបង្គោល គំរូ
- រៀបចំចងក្រងបណ្តាញគ្រូឧទ្ទេស គ្រូបង្គោល អ្នកវាយតម្លៃបង្គោល សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវក្នុងវិស័យទេសចរណ៍
- សហការរៀបចំការលើកទឹកចិត្ត និងផ្តល់រង្វាន់ដល់អ្នកជំនាញទេសចរណ៍ និងប្រតិបត្តិករទេសចរណ៍គំរូដែលបានផ្តល់សេវា និងបដិសណ្ឋារកិច្ចល្អ
- សហការរៀបចំបើកវគ្គបណ្តុះបណ្តាលដើម្បីគាំទ្រដល់យុទ្ធនាការផ្សព្វផ្សាយទេសចរណ៍ផ្សេងៗ ដូចជាចលនាប្រលងប្រណាំងបដិសណ្ឋារកិច្ចល្អ និងយុទ្ធនាការ Cambodia Feel the Warmth ។ល។ ក្នុងនោះរួមមានការផ្សព្វផ្សាយពីច្បាប់ បទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំផ្សេងៗ
- សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិបត្តិករទេសចរណ៍ សហគ្រាសខ្នាតតូច និងមធ្យមក្នុងវិស័យទេសចរណ៍ និងដៃគូអភិវឌ្ឍន៍បើកវគ្គបណ្តុះបណ្តាលផ្សេងៗរួមមានវគ្គបណ្តុះបណ្តាលខាងក្នុង (In-House Training)។ល។
- សហការត្រួតពិនិត្យ វាយតម្លៃ ទទួលស្គាល់ និងតាមដានការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍សំដៅធានាឱ្យមានការបណ្តុះបណ្តាលប្រកបដោយគុណភាព និងស្របតាមស្តង់ដា និងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍កម្រិតជាតិ និងអន្តរជាតិ អាស៊ាន តំបន់ និង ពិភពលោក
- សហការជាមួយនាយកដ្ឋានធនធានមនុស្ស នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន និងភាគីពាក់ព័ន្ធ រៀបចំផែនការយុទ្ធសាស្ត្រ និងស្វែងរកជំនួយបច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីធ្វើការបណ្តុះបណ្តាលមន្ត្រីរាជការនៅទីស្តីការក្រសួង និងមន្ទីរទេសចរណ៍រាជធានី ខេត្ត
- សហការអនុវត្តវិធានការ និងរៀបចំកម្មវិធីបណ្តុះបណ្តាលនានាសំដៅលើកកម្ពស់ និងធានាគុណភាពធនធានមនុស្សក្នុងវិស័យទេសចរណ៍។

**៦-ការិយាល័យបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- រៀបចំបើកវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់កម្រិត
- រៀបចំការប្រលងចូល ប្រលងចេញ និងប្រកាសលទ្ធផលសម្រាប់មគ្គុទ្ទេសក៍ទេសចរណ៍
- ផ្តល់វិញ្ញាបនបត្របណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់កម្រិត
- សិក្សាអំពីតម្រូវការបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់កម្រិត
- សហការអភិវឌ្ឍ និងធ្វើបច្ចុប្បន្នកម្មស្តង់ដាសមត្ថភាព និងកម្មវិធីបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍ឱ្យបានគ្រប់កម្រិត
- សហការជាមួយគ្រឹះស្ថានសិក្សាទេសចរណ៍ និងបដិសណ្ឋារកិច្ច និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ដើម្បីរៀបចំបើកវគ្គបណ្តុះបណ្តាលមគ្គុទ្ទេសក៍ទេសចរណ៍គ្រប់កម្រិត។

**៧-ការិយាល័យចុះបញ្ជី និងទីផ្សារការងារជំនាញវិជ្ជាជីវៈទេសចរណ៍** មានតួនាទី និងភារកិច្ចៈ

- ចុះបញ្ជីអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន
- ជម្រុញការចុះបញ្ជីអ្នកជំនាញលើប្រព័ន្ធចុះបញ្ជីអ្នកជំនាញទេសចរណ៍ជាតិ និងអាស៊ាន
- ធ្វើបច្ចុប្បន្នកម្មព័ត៌មានទាក់ទងនឹងការពង្រឹង និងអភិវឌ្ឍន៍ជំនាញវិជ្ជាជីវៈទេសចរណ៍
- រៀបចំ និងបោះពុម្ពព្រឹត្តិបត្រផ្សព្វផ្សាយអំពីជំនាញវិជ្ជាជីវៈទេសចរណ៍ និងតម្រូវការការងារជំនាញវិជ្ជាជីវៈទេសចរណ៍ក្នុងទីផ្សារការងារ
- ប្រឹក្សាយោបល់ទាក់ទងទៅនឹងទីផ្សារការងារក្នុងវិស័យទេសចរណ៍
- សហការរៀបចំព្រឹត្តិការណ៍ជំនាញទេសចរណ៍ រួមមានវេទិកាអ្នកជំនាញទេសចរណ៍ វេទិកាអាជីពទេសចរណ៍ថ្នាក់ជាតិ ការប្រកួតជំនាញទេសចរណ៍ ពិព័ណ៌ការងារក្នុងវិស័យទេសចរណ៍
- សហការជាមួយគ្រឹះស្ថានសិក្សាទេសចរណ៍ និងបដិសណ្ឋារកិច្ច និងសាលាបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ដើម្បីសម្រួលដល់ការស្វែងរកការងាររបស់សិស្ស និងនិស្សិតដែលសិក្សាជំនាញទេសចរណ៍
- សហការជាមួយប្រតិបត្តិករទេសចរណ៍ រៀបចំឱ្យមានការផ្តល់ឱកាសធ្វើការងារសាកល្បងក្នុងវិស័យទេសចរណ៍ សំដៅជម្រុញឱ្យមានការផ្តល់ឱកាសការងារសាកល្បង និងកម្មសិក្សាកាន់តែច្រើនដល់សិស្ស និស្សិត និងអ្នកជំនាញទេសចរណ៍ (Internship, Traineeship and Apprenticeship)។

**ប្រការ ៦.-**

ការិយាល័យនីមួយៗចំណុះឱ្យនាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ មានតួនាទី និងភារកិច្ចៈ

- ធ្វើកំណត់ហេតុប្រជុំ ដែលពាក់ព័ន្ធនឹងការងារទទួលខុសត្រូវរបស់ខ្លួន
- រៀបចំគម្រោងផែនការសកម្មភាពការងារ និងថវិកាចំណាយផ្សេងៗ និងប្រចាំឆ្នាំរបស់ខ្លួនជូនប្រធាននាយកដ្ឋាន
- ធ្វើរបាយការណ៍សកម្មភាពការងារប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំរបស់ការិយាល័យជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធាននាយកដ្ឋាន ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន នាយកវិទ្យាស្ថានជាតិទេសចរណ៍ អគ្គាធិការ នៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធនធានមនុស្ស ប្រធាននាយកដ្ឋានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទេសចរណ៍ ប្រធានគ្រប់អង្គភាពចំណុះក្រសួងទេសចរណ៍ ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ថោង ខុន**

កន្លែងទទួល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ